នៅថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០០៨ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) បានរៀបចំដំណើរទស្សនកិច្ចមួយជូនដល់ក្រុមភ្នាក់អភិវឌ្ឍន៍សហរដ្ឋអាមេរិក (USAID) ទស្សនាកសិដ្ឋានប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស) នៅស្រុកត្រាំកក់ ខេត្តតាកែវ ។ ក្រុមទស្សនកិច្ចដែលមានគ្នាចំនួន ១១ នាក់ (ស្ត្រី ៤ នាក់) រួមទាំងអ្នកកាសែត និងវិទ្យុបរទេសចំនួនពីររូប បានអញ្ជើញទៅទស្សនាកសិដ្ឋានរបស់កសិករ ***រស់ ម៉ៅ*** នៅភូមិចោមពុល ឃុំពពេល ស្រុកត្រាំកក់ខេត្តតាកែវ ដែលមានលោកបណ្ឌិត ***យ៉ង សាំងកុមារ*** ប្រធានអង្គការសេដាក ជាអ្នកដឹកនាំ។ ក្នុងកំឡុងដំណើរទស្សនកិច្ចកសិករ ***រស់ ម៉ៅ*** បានជំរាបប្រាប់ដល់ក្រុមទស្សនកិច្ច ក៏ដូចជាអ្នកកាសែតអន្តរជាតិអំពីប្រវត្តិនៃការដាំដុះ ការរៀបចំដីកសិដ្ឋានរបស់លោក ក៏ដូចជាការដកពិសោធន៍ការដាំដុះដំណាំ និងបន្លែគ្រប់ប្រភេទ និងអំពីប្រាក់ចំណូលដែលលោករកបានពីកសិដ្ឋានរបស់លោក ។ លោកឱ្យដឹងថា ប្រែក្លាយពីការខ្វះខាត ទៅស៊ីឈ្នួលនៅទីក្រុងភ្នំពេញដើម្បីរកប្រាក់ចំណូលបន្ថែម តែនៅតែមិនគ្រប់ឥឡូវ ក្រោយការសហការជាមួយអង្គការសេដាក ប្រាក់ចំណូលរបស់គាត់ដែលរកបានពីកសិដ្ឋានរបស់គាត់មានរហូតដល់ទៅ ៧ ទៅ ៨ លានរៀល ក្នុងមួយឆ្នាំ។ កសិករ ***រស់ ម៉ៅ*** ក៏បានជំរាប់ប្រាប់ដល់ក្រុមទស្សនកិច្ចអំពីការលំបាករបស់គាត់មួយចំនួនទាក់ទងនឹងការដាំដុះរបស់គាត់ចាប់តាំងពីផ្តើមសហការជាមួយអង្គការសេដាក នៅឆ្នាំ ២០០៣ មក ដោយសូម្បីតែប្រពន្ធរបស់គាត់ក៏មិនមានទំនុកចិត្តលើបច្ចេកទេសដាំដុះថ្មីរបស់អង្គការសេដាក ពិសេសបច្ចេកទេស ប.វ.ស ដែរ ដែលវាផ្ទុយស្រឡះពីឥឡូវកុំថាឡើយតែគ្រួសាររបស់គាត់ សូម្បីតែអ្នកភូមិរបស់គាត់ និងអ្នកភូមិក្បែរខាង ក៏មានការចាប់អារម្មណ៍ និងកំពុងទទួលយកការបណ្តុះបណ្តាល និងណែនាំពីរូបលោក។



បន្ទាប់ពីការដើរទស្សនា និងថតរូបដំណាំបន្លែនៅកសិដ្ឋានរបស់លោក ***រស់ ម៉ៅ*** រួចមក ក្រុមទស្សនកិច្ចបានបន្តដំណើរទៅមើលកសិដ្ឋានរបស់កសិករ ***ប្រាក់ ច្រេស*** ដែលជាកសិករដំបូងគេ និងជាកសិករឆ្នើមខាងការផលិតពូជ។ ក្រោយការស្តាប់បទបង្ហាញជាសង្ខេបអំពីកសិដ្ឋានរបស់លោកតា ***ប្រាក់ ច្រេស*** និងធ្វើការសាកសួររួចមក ក្រុមទស្សនកិច្ចបានពិសារអាហារថ្ងៃត្រង់នៅផ្ទះលោកតា ***ប្រាក់ ច្រេស*** បន្ទាប់មកទៅទស្សនាកសិដ្ឋានរបស់លោក។ នៅពេលរសៀល ក្រុមទស្សនកិច្ចក៏បានបន្តដំណើរទៅជួបប្រជុំជាមួយក្រុមសហគមន៍ផលិតស្រូវសិរីរាង្គ និងទៅទស្សនាតំបន់ព្រៃការពារនៅភូមិត្រពាំងឈូក ឃុំត្រពាំធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។

បន្ទាប់ពីដំណើរទស្សនកិច្ចពេញមួយថ្ងៃ ដោយធ្វើការជួបជាមួយកសិករ ក្រុមតំណាង USAID បានសំដែងនូវការសប្បាយរីករាយ និងថ្លែងអំណរគុណចំពោះអង្គការសេដាក ដែលបានធ្វើការយ៉ាងជិតស្និតជាមួយកសិករ និងសន្យាមកទស្សនាម្តងទៀតនៅរដូវច្រូតកាត់ប្រមូលផលស្រូវ។